ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ១២៥ បទ.ប្រក

ភ្នំពេញ, ថ្ងៃទី ១២ ខែ ០៥ ឆ្នាំ ២០០៤

# ប្រ ក ា ស

## ស្តីពីការ បង្កើតគណៈកម្មការរៀបចំគំរោងសំរាប់ការអភិវឌ្ឍន៍លើវិស័យទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ / បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-យោងតាមការងារចាំបាច់របស់ក្រសួង

## ស ំ រ េ ច

**ប្រការ១ :** ត្រូវបានបង្កើតគណៈកម្មការមួយ របស់ក្រសួង ដើម្បីរៀបចំ គំរោងសំរាប់ការអភិវឌ្ឍន៍ លើវិស័យទូរគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ផាន់ ភិន | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម ឡា | ណារ៉ាត | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម ភួយ | គីមស៊ា | អនុរដ្ឋលេខាធិការ | សមាជិក |

៤-ឯកឧត្តម ឡុង វ៉ាន់ហាន អនុរដ្ឋលេខាធិការ សមាជិក
៥-ឯកឧត្តម ភុយ ពុំ អគ្គនាយករដ្ឋបាល សមាជិក
៦-ឯកឧត្តម នូច ហេង អគ្គនាយកប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក
៧-លោក ញាណា ស្រស់ អគ្គនាយករង រដ្ឋបាល សមាជិក
៨-លោក កែវ ចន្ទឿន អគ្គនាយករង រដ្ឋបាល សមាជិក
៩-លោក មាស ប៊ុ អគ្គនាយករង ប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក
១០-កញ្ញា ឡេ ម៉ាយអៀង អគ្គនាយករង ប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក
១១-លោក ព្រុំ សុន្ធារ អគ្គនាយករង ប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក
១២-លោក ឡាយ ម៉ារីទ្ធ័ អគ្គនាយករង រដ្ឋបាល សមាជិក
១៣-លោក លី សំអាន ប្រធាននាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ សមាជិក
១៤-លោក ឆេព ម៉ិន្ថា ប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ សមាជិក
១៥-លោក ស៊ា ណារ៉េត ប្រធាននាយកដ្ឋានរលកអាកាសវិទ្យុ និងអាជ្ញាប័ណ្ណ សមាជិក
១៦-លោក គិម ទិត្រា អនុប្រធាននាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ សមាជិក
១៧-លោក ម៉ុច ចរិយា អនុប្រធាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ សមាជិក
១៨-លោក ឡេង បុគន្ធ ប្រធានការិយាល័យបូកសរុប និងស្ថិតិ ជំនួយការ
១៩-កញ្ញា ឌុន ណារិទ្ធិ ប្រធានការិយាល័យផែនការ ជំនួយការ
២០-លោក គុល ញ៉ាក់ អនុប្រធានមជ្ឈមណ្ឌលបញ្ជូនស៊ីញ៉ាល់ ជំនួយការ

**ប្រការ២** : គណៈកម្មការនេះ មានភារកិច្ច ដូចតទៅ ÷

២.១- ជាជំនួយការជូនដល់ ***ឯកឧត្តមរដ្ឋមន្ត្រី*** ក្នុងការរៀបចំគំរោងលំអិត ស្តីពីការ អភិវឌ្ឍន៍ វិស័យទូរគ-នាគមន៍ ក្នុងក្របខ័ណ្ឌកំណត់ទឹកប្រាក់ ដែលស្ថិតក្នុងក្របខ័ណ្ឌ ជាប្រាក់កម្ចី និង ជំនួយពីបរទេស ។

២.២- សហការជាមួយគ្រប់អង្គភាព និង អន្តរក្រសួងនានា ដែលមានការពាក់ព័ន្ធ មានជាអាទិ៍ : ការងារបច្ចេ ទេសជំនាញ , ការវិភាគគំរោងសេដ្ឋកិច្ច.......... ។ល ។ ក្នុងការរៀបចំបណ្តាគំរោងអភិវឌ្ឍន៍ទាំងនោះ ។

២.៣- ចូលរួមសំរបសំរួល និង ពិភាក្សាជាមួយម្ចាស់អំណោយ ក្នុងករណីមានសំណូមពរ ដើម្បីទទួលបានប្រសិទ្ធ ភាពនិងលទ្ធផលល្អ ក្នុងកិច្ចដំណើរការរៀបចំបណ្តាគំរោងខាងលើនេះ ។

២.៤- ពេលបញ្ចប់ការងាររបស់ខ្លួន គណៈកម្មការនេះ ត្រូវរៀបចំធ្វើការបូកសរុបពីលទ្ធផលការងារ រៀបចំ បណ្តា គំរោងអភិវឌ្ឍន៍ទាំងអស់នោះ និងលើកជាយោបល់ ជូន ***ឯកឧត្តមរដ្ឋមន្ត្រី*** ដើម្បីសុំការពិនិត្យ សំរេច

២.៥- គណៈកម្មការត្រូវចូលរួមប្រជុំ តាមការអញ្ជើញ របស់ ***ឯកឧត្តមប្រធាន*** ។

**ប្រការ៣** : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** : អគ្គនាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋាន ប.ទ-នាយកដ្ឋានប្រៃសណីយ៍-នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ-នាយកដ្ឋានទូរគមនាគមន៍ ក្នុងប្រទេស និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍ តាមខ្លឹមសារ នៃប្រកាសនេះ ។

**ប្រការ៥** : ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**កន្លែងទទួល**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៤ "ដើម្បីអនុវត្តន៍"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ